# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា
## អំពី
# ច្បាប់អំពីការយាយី

*តើអ្វីទៅជាការយាយីដែលល្មើសច្បាប់?*

ការយាយីគឺជាការប្រព្រឹត្តតាម ពាក្យសំដី ការសរសេរ ក្រាហ្វិក ឬ រាងកាយ ដែលទាក់ទងទៅនឹង ភេទ អាយុ ពូជសាសន៍ ពណ៌សម្បុរ ទំនោរចិត្តចំពោះផ្លូវភេទ (បានដឹង ឬតាមការយល់ឃើញ) ការបង្ហាញពីអត្តសញ្ញាណអំពីភេទ (បានដឹង ឬតាមការយល់ឃើញ) ជាតិកំណើត សាសនា ពិការភាព មានឬក្រ និង/ឬ ដោយសារតែគោលជំហរនយោបាយ របស់ជនណាម្នាក់។

*តើឧទាហរណ៍នៃអាកប្បកិរិយាដែលត្រូវហាមឃាត់ មានអ្វីខ្លះ?*

- ***ការគម្រាមកំហែងឬយាយី ការសម្លុតឬវាយតប់ សិស្សដទៃទៀត***
- ***ការគូសវាសលេងខុសច្បាប់ (graffiti) ដែលមានពាក្យបណ្ដាលឲ្យអ្នកដទៃអាក់អន់ចិត្ត ដែលប្រមាថមើលងាយដល់អ្នកដទៃ***
- ***និយាយបង្អាប់ ឬប្រើឈ្មោះបង្អាប់ ឬនិយាយឡកឡឺយ ទៅកាន់អ្នកដទៃទៀត***
- ***ការវាយតម្លៃអាក្រក់ដល់ក្រុមណាមួយ ឬអំពើដែលជាសត្រូវ ដែលប្រមាថមើលងាយដល់អ្នកដទៃ***
- ***ការសរសេរ ឬក្រាហ្វិក ដែលមាន ពាក្យ ឬ ការវាយតម្លៃអាក្រក់ដល់ក្រុមណាមួយ ដែល បិទប្រកាស ផ្សាយ ឬ សរសេរ ឬបោះពុម្ព នៅលើសម្ភៀកបំពាក់ ដែលប្រមាថមើលងាយដល់អ្នកដទៃ***

*ក្រសួងអប់រំហាមឃាត់ការយាយីគ្រប់យ៉ាង ដែលប្រព្រឹត្តដោយសិស្សានុសិស្សរបស់ក្រសួង*

*តើអ្នកគួរធ្វើដូចម្ដេច បើខ្លួនអ្នក ឬអ្នកណាម្នាក់ដែលអ្នកស្គាល់ ត្រូវគេយាយី?*

**រាយការណ៍ពីឧបត្តិហេតុនៃការយាយី៖**

- សិស្ស ឬ មាតាបិតា/អាណាព្យាបាល របស់សិស្សដែលត្រូវគេយាយី ឬសាក្សីនៃការយាយី គួររាយការណ៍ឧបត្តិហេតុនេះ ទៅនាយកសាលា ឬអ្នកតំណាង ឬសមាជិកដទៃទៀតនៃបុគ្គលិកសាលា រួមទាំង គ្រូបង្រៀន អ្នកផ្ដល់ឱវាទ គ្រូកីឡា និងបុគ្គលិករដ្ឋបាល។
- បុគ្គលិកណាដែលទទួលសេចក្ដីរាយការណ៍នេះ នឹងជម្រាបទៅនាយកសាលា ឬអ្នកតំណាងរបស់គាត់ ជាបន្ទាន់។
- ប្រសិនបើការយាយីនេះនៅតែមានជាបន្ត ឬប្រសិនបើសាលាមិនរកវិធីដោះស្រាយទេនោះ សិស្ស ឬ មាតាបិតា/អាណាព្យាបាល គួររាយការណ៍ឧបត្តិហេតុនេះ ទៅបណ្ដាញខ្សែទូរស័ព្ទសម្រាប់ការយាយីរបស់ក្រសួងអប់រំលេខ ២១៥-៤០០-SAFE។

*តើមានអ្វីកើតឡើង នៅពេលឧបត្តិហេតុនៃការយាយី ត្រូវបានគេរាយការណ៍ហើយ?*

គេនឹងធ្វើការស៊ើបអង្កេតឲ្យបានឆាប់រហ័ស ហើយដោយហ្មត់ចត់ នូវគ្រប់សេចក្ដីរាយការណ៍ទាំងអស់។ ប្រសិនបើពាក្យចោទប្រកាន់នេះជាការពិត នាយកសាលា ឬអ្នកតំណាងរបស់គាត់ នឹងធ្វើសកម្មភាពដូចតទៅ៖

- ផ្ដល់ដំណឹងទៅសិស្សដែលយាយីគេ អំពីលទ្ធផលនៃការស៊ើបអង្កេតនេះ
- ពិនិត្យមើលឡើងវិញអំពីអត្ថន័យនៃការយាយី និងច្បាប់របស់ក្រសួងអប់រំ ស្ដីអំពីការយាយី
- ដាក់ទណ្ឌកម្មទៅលើអាកប្បកិរិយានេះទៅតាម ចំនួន និងទម្ងន់ នៃអាកប្បកិរិយា និង
- ផ្ដល់ដំណឹងទៅមាតាបិតារបស់សិស្សដែលយាយីគេ រួមទាំង សកម្មភាពរបស់សិស្ស និងលទ្ធផលនៃអំពើទាំងនោះ។

*តើនឹងមានអ្វីកើតឡើងដល់សិស្សដែលយាយីគេ?*

*លទ្ធផលចំពោះការល្មើសច្បាប់៖*

- សិស្សដែលល្មើសនឹងច្បាប់យាយី នឹងត្រូវទទួលវិន័យ ទៅតាមក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស។
- ប្រសិនបើបទល្មើសលើកទីមួយជាបទល្មើសដែលធ្ងន់ធ្ងរ គឺអាចបណ្ដាលឲ្យមានការបញ្ឈប់មិនឲ្យមករៀនអស់រយៈពេលយូរ (៤-១០ថ្ងៃ) បញ្ជូនទៅកម្មវិធីអប់រំតាមវិធីផ្សេងទៀត ឬបណ្ដេញចេញ។

***ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទាក់ទងមក ការិយាល័យផ្នែក វិន័យ សវនាការ និងការបណ្ដេញសិស្សចេញ (Office of Student Discipline, Hearings and Expulsions) លេខ (២១៥) ៤០០-៤២៣០***